មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ៨

# ៥ - បីតិចេតសិក (Joy)

**បីនយតិ កាយចិត្តំ តប្បេតិ វឌ្ឍេតីតិ វា = បីតិ** ធម្មជាតិដែលឈ្មោះថា **បីតិ** ព្រោះអត្ថថា ញ៉ាំងកាយ និងចិត្តឲ្យឆ្អែតឲ្យរីករាយ ឬញ៉ាំងកាយនិងចិត្តឲ្យចម្រើន ដូចផ្កាបទុមរីកល្អហើយ។

ស្កេនដើម្បីមើលមេរៀន
San Sochea Official

# លក្ខណាទិចតុក្កៈរបស់បីតិ

| | |
|---|---|
| ១ - សម្បិយាយនលក្ខណា | មានការស្រស់ស្រាយ សប្បាយ ពេញចិត្ត ជាលក្ខណៈ |
| ២ - កាយចិត្តសម្បីណនរសា | មានការធ្វើឲ្យកាយនិងចិត្តឆ្អែត ជាកិច្ច |
| ៣ - ឱទគ្យបច្ចុប្បដ្ឋានា | មានការត្រេកអររីករាយ ជាអាការប្រាកដ |
| ៤ - សេសខន្ធត្តយបទដ្ឋានា | មាននាមខន្ធ ៣ *(គឺ វេទនាខន្ធ សញ្ញាខន្ធ និងវិញ្ញាណក្ខន្ធ)* ដែលនៅសល់ ជាហេតុជិត។ |

# បីតិ ៥ យ៉ាង

១ - ខុទ្ទកាបីតិ សេចក្តីត្រេកអរតិច ត្រឹមព្រឺរោម ព្រឺស្បែក ដែលកើតឡើងម្តងម្កាល

២ - ខណិកាបីតិ សេចក្តីត្រេកអរមួយខណៈៗ ប្រាកដដូចជាផ្លេកបន្ទោរ *(តាំងនៅមិនយូរ)*

៣ - ឱក្កន្តិកាបីតិ សេចក្តីត្រេកអរមួយស្របក់ មានអាការប្រាកដដូចជាទឹករលកបោកខ្ទប់ច្រាំង ហើយក៏បែកទៅ

៤ - ឧព្វេង្គាបីតិ សេចក្តីត្រេកអរខ្លាំង អាចញ៉ាំងកាយឲ្យអណ្តែតឡើង

៥ - ផរណាបីតិ សេចក្តីត្រេកអរធ្វើឲ្យផ្សព្វផ្សាយជ្រួតជ្រាបទូទៅក្នុងកាយ ដូចសំឡីជប់ទឹក។

# ៦ - ឆន្ទចេតសិក (Conation)

ឆន្ទនំ = ឆន្ទោ សេចក្ដីពេញចិត្ត ឈ្មោះថា ឆន្ទៈ។

ឆន្ទៈនេះ មានការប្រាថ្នារូបារម្មណ៍ជាដើម។

# លក្ខណាទិចតុក្កៈរបស់ឆន្ទៈ

១ - កត្តុកម្យតាលក្ខណោ មានការប្រាថ្នាដើម្បីធ្វើ ជាលក្ខណៈ

២ - អារម្មណបរិយេសនរសោ មានការស្វែងរកអារម្មណ៍ ជាកិច្ច

៣ - អារម្មណេន អត្ថិកតាបច្ចុប្បដ្ឋានោ មានសេចក្តីប្រាថ្នាត្រូវការអារម្មណ៍ ជាអាការប្រាកដ

៤ - អារម្មណបទដ្ឋានោ មានអារម្មណ៍ ជាហេតុជិត។

បកិណ្ណកចេតសិកទាំង ៦ នេះ ជាសង្ខារក្ខន្ធទាំងអស់ មិនចាំបាច់ចែកដោយន័យផ្សេង ៗ ទេ ព្រោះប្រកបជាមួយនឹងចិត្តយ៉ាងណា ចេតសិកទាំង ៦ នេះ ក៏ជាយ៉ាងនោះ។

# សរុបអញ្ញសមានាចេតសិក ១៣

អញ្ញសមានាចេតសិក១៣

- សព្វចិត្តសាធារណចេតសិក ៧
  - ផស្សៈ
  - វេទនា
  - សញ្ញា
  - ចេតនា
  - ឯកគ្គតា
  - ជីវិតិន្ទ្រីយ៍
  - មនសិការៈ
- បកិណ្ណកចេតសិក ៦
  - វិតក្កៈ
  - វិចារៈ
  - អធិមោក្ខៈ
  - វិរិយៈ
  - បីតិ
  - ឆន្ទៈ

ចប់ អញ្ញសមានាចេតសិក

# អធិប្បាយ អកុសលចេតសិក ១៤

អកុសលចេតសិកទាំង ១៤ នេះ ជាចេតសិកផ្នែកអាក្រក់ ជាបាប កាលប្រកបជាមួយនឹងចិត្ត រមែងធ្វើ ឲ្យចិត្តសៅហ្មង។ អកុសលចេតសិកទាំង ១៤ នេះ កើតតែនៅក្នុងចិត្តជាអកុសលចិត្ត ១២ ដួង ប៉ុណ្ណោះ។

# អកុសលចេតសិក ១៤ មាន ៥ ន័យ

១ - មោចតុក្កៈ    បានដល់ ចេតសិក ៤ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ

២ - លោតិកៈ    បានដល់ ចេតសិក ៣ គឺ លោភៈ ទិដ្ឋិ មានៈ

៣ - ទោចតុក្កៈ    បានដល់ ចេតសិក ៤ គឺ ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ

៤ - ថីទុកៈ    បានដល់ ចេតសិក ២ គឺ ថីនៈ មិទ្ធៈ

៥ - ឯកវិចិកិច្ឆា    បានដល់ ចេតសិក ១ គឺ វិចិកិច្ឆា